

លេខ ១៨

# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

ខែ មេសា ឆ្នាំ ២០១៤

ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

## ព្រឹត្តិការណ៍សំខាន់ៗ

- សៀវភៅសិក្សាបំណិនជីវិតជាង៩០% ត្រូវបានអនុម័ត និងទទួលយកដោយ ក្រសួង អយក
- អនុវិទ្យាល័យចំនួន១១៣ កំពុង បង្រៀនកម្មវិធីបំណិនជីវិត
- សិស្សអនុវិទ្យាល័យសរុបចំនួន ២៣,០០០នាក់កំពុងទទួលផលពី កម្មវិធីបំណិនជីវិត ក្នុងខេត្តគោលដៅទាំងប្រាំមួយ
- គ្រូសហគមន៍ចំនួន៣៩នាក់បានទទួល ការគាំទ្រផ្ទាល់ពី IBEC
- សិស្សានុសិស្សដែលបោះបង់ចោល ការសិក្សាជាង៩០%បានត្រឡប់មក សិក្សាវិញតាមរយៈបណ្តាញមិត្តអប់រំមិត្ត




ឯ.ឧ. បណ្ឌិត ហង្ស ជួនណារ៉ុន បើកពិធីសម្ពោធជាផ្លូវការនូវសៀវភៅអប់រំបំណិនជីវិតដែលបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួង អយក

កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ IBEC បានប្រារព្ធពិធីសម្ពោធជាផ្លូវការនូវសៀវភៅអប់រំបំណិនជីវិតចំនួន៣០ប្រធានបទដែលបង្កើតឡើងដោយ IBEC ។ សៀវភៅ បំណិនជីវិតនេះនឹងជួយសាលារៀនកម្ពុជាក្នុងការលើកកម្ពស់វិធីសាស្ត្រសិក្សារបស់សិស្ស ខណៈពេលដែលកម្មវិធីសិក្សានេះមានភាពពាក់ព័ន្ធ និងការអនុវត្តច្រើនទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។ កម្មវិធី បំណិនជីវិតគឺជាគោលដៅចម្បងរបស់គម្រោង និងមានកិច្ចសហការយ៉ាងខ្លាំងរវាងក្រសួង អយក USAID អង្គការអប់រំពិភពលោក និង KAPE ។ លោកស្រី Rebecca Black នាយិកាបេសកកម្ម USAID ប្រចាំកម្ពុជា ឯ.ឧ. បណ្ឌិត ហង្ស ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងលោកជំទាវ បណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី អញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធនោះ ។



បំណិនជីវិត



បច្ចេកវិទ្យា



ក្រុមប្រឹក្សាកុមារ

USAID FROM THE AMERICAN PEOPLE

អង្គការអប់រំពិភពលោក WORLD EDUCATION

## សិក្ខាសាលាស្តីពីការអនុវត្តល្អ



សិក្ខាសាលាស្តីពីការអនុវត្តល្អផ្សព្វផ្សាយដល់គ្រប់អ្នកពាក់ព័ន្ធ

IBEC បានរៀបចំសិក្ខាសាលាស្តីពីការអនុវត្តល្អដល់ដៃគូអភិវឌ្ឍន៍ និងដៃគូរដ្ឋាភិបាលនានា កាលពីថ្ងៃទី ៧ ខែមីនា ឆ្នាំ២០១៤ នៅសណ្ឋាគារកាំបូឌីយ៉ាណាទីក្រុងភ្នំពេញ ។ សិក្ខាសាលានេះមានគោលបំណងដើម្បីសង្ខេបនូវចំណុចសំខាន់ៗដែល IBEC បានជួបចាប់តាំងពីគម្រោងបានចាប់ផ្តើម ។ ចំណុចសំខាន់ទាំងនេះមានច្រើន និងខុសៗគ្នា ដោយផ្តោតលើការដោះស្រាយកង្វះខាតគ្រូតាមរយៈការជ្រើសរើសគ្រូនៅតាមតំបន់ទាំងនោះ ការណែនាំអំពីបច្ចេកវិទ្យា ICT ដែលធានាបាននូវនិរន្តរភាព កសាងភាពជាម្ចាស់ក្នុងតំបន់តាមរយៈការប្រើបញ្ជីសកម្មភាព និងការសម្រេចបាននូវវិធីសាស្រ្តគាំទ្រចម្បងសម្រាប់ផែនការអភិវឌ្ឍន៍សាលារៀនពីអាជ្ញាធរក្នុងតំបន់ ជាពិសេសការជួយគាំទ្រពីក្រុមប្រឹក្សាឃុំ ។ ការពិនិត្យឡើងវិញនូវចំណុចសំខាន់ៗជាច្រើនក្នុងគោលបំណងធ្វើការអភិវឌ្ឍន៍ និងផ្សព្វផ្សាយការអប់រំបំណិនជីវិត ចាប់តាំងពីគោលនយោបាយស្តីពីបំណិនជីវិតត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ២០០៦មក ។ សិក្ខាសាលាមានបំណងចង់បង្ហាញជាលក្ខណៈផ្ទៃក្នុងថា តើការរៀបចំនូវកម្មវិធីសិក្សាបំណិនជីវិតថ្មីនេះ បានជោគជ័យយ៉ាងដូចម្តេច បន្ទាប់ពីធ្វើការសាកល្បងក្នុងឆ្នាំ២០០២រួចមក។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមគណៈអធិបតីភាពរបស់ ឯ.ឧ. ទូច សារ៉ូ អនុរដ្ឋលេខាធិការក្រសួង អយក និងមានការចូលរួមពីមន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍផ្សេងៗ ជាង ១០០នាក់ ។ IBEC បានប្រើប្រាស់ឱកាសនេះដើម្បីចែកចាយនូវសៀវភៅបំណិនជីវិត របាយការណ៍ស្រាវជ្រាវ និងឯកសារបច្ចេកទេសជាច្រើនទៀតដែលបង្កើតឡើងដោយ IBEC ចាប់តាំងពីគម្រោងនេះបានចាប់ផ្តើមក្នុងឆ្នាំ២០០៩ ។

## សមាសភាគ១ ៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងស្វែងរកការគាំទ្រដើម្បីនិរន្តរភាព

### សិក្ខាសាលាស្តីពីផែនការនិរន្តរភាព

ការគាំទ្រថវិកាដល់សាលាបឋមសិក្សាចំនួន៦១ និងសាលាអនុវិទ្យាល័យចំនួន៧០ ក្នុងខេត្តកំពង់ចាម ក្រចេះ និងសៀមរាបត្រូវបានបញ្ចប់ចាប់តាំងពីចុងឆ្នាំទី៤មកម្លេះ។ ថវិកាគាំទ្រសាលារៀនទាំងនេះត្រូវបានកាត់បន្ថយច្រើនក្នុងពេលបច្ចុប្បន្ន ដោយផ្អែកតាមផែនការនិរន្តរភាពតាមសាលារៀនមួយៗ ហើយថវិកាទាំងនេះត្រូវបាន ផ្តល់ទៅសាលារៀនតាមរយៈក្រុមប្រឹក្សាឃុំជាមួយ នឹងទុនបដិភាគពីថវិកាអភិវឌ្ឍន៍ឃុំ ។ ក្រុមការងារក្នុងសមាសភាគនេះបានធ្វើការជាមួយសាលារៀន និងអាជ្ញាធរក្នុងតំបន់លើដំណើរការកាត់បន្ថយជំនួយចាប់តាំងពីចុងឆ្នាំទី៣មក ។ ក្នុងឆ្នាំកន្លងមកសាលារៀនទទួលបានជំនួយក្នុងការអភិវឌ្ឍផែនការនិរន្តរភាពទៅថ្ងៃអនាគត និងរៀនអំពីរបៀបកំណត់សកម្មភាពអទិភាពរបស់ពួកគេ ផ្អែកលើតម្រូវការ និងធនធានដែលអាចរកបានក្នុងតំបន់ ។ ក្នុងត្រីមាសនេះ ក្រុមការងារបានដឹកនាំសិក្ខាសាលាជុំចុងក្រោយមួយ ដើម្បីផ្ទុះបញ្ចាំងពីផែនការនិរន្តរភាពដែលអាចធ្វើទៅបាន ចាប់ផ្តើមពីការកំណត់នូវធនធានដែលអាចរកបានក្នុងតំបន់ ។ នាយកសាលា មេឃុំ និងអ្នកពាក់ព័ន្ធដទៃទៀតត្រូវបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាចុងក្រោយនេះ ។ ចំណុចសំខាន់ៗក្នុងពេលសិក្ខាសាលាគឺការបង្កើតកិច្ចសហការរវាងសាលារៀន និងអាជ្ញាធរក្នុងតំបន់ដើម្បីឱ្យមានទំនាក់ទំនង និងការសហការកាន់តែខ្លាំងក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ ។

### ទុនបដិភាគ និងក្រុមប្រឹក្សាឃុំ

ចាប់តាំងពីខែមករា ឆ្នាំ២០១៤មក ឃុំបានចំណាយថវិកាសរុបចំនួន $២០,១៣០ ដល់សាលារៀនគឺស្មើនឹង៨៤%នៃថវិកាសរុបដែលមាន ។ ឃុំទាំង២៥បានចុះកិច្ចសន្យាជាមួយ IBEC ស្តីពីការផ្តល់ទុនបដិភាគរួចរាល់ហើយកាលពីខែ វិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៣ ហើយវគ្គបំប៉នស្តីពីការធ្វើបុរេប្រទាន និងការទូទាត់ក៏ត្រូវបានធ្វើរួចរាល់ក្នុងពេលនោះដែរ សម្រាប់ខេត្តគោលដៅទាំង៣ ដូចដែលបានធ្វើរបាយការណ៍ក្នុងត្រីមាសមុន ។ បន្ទាប់ពីវគ្គបំប៉នមកឃុំបានដាក់សំណើសុំថវិកា ក្នុងគោលបំណងចាប់ផ្តើមអនុវត្តសកម្មភាព ។ កិច្ចប្រជុំតាមដានបានធ្វើឡើងជាបន្តបន្ទាប់ក្នុងអំឡុងពេលត្រីមាសនេះដើម្បីឱ្យប្រាកដថាការចាយវាយ និងការអនុវត្តបានកំពុងដំណើរការ។ ក្រុមប្រឹក្សាឃុំជាអ្នកទទួលខុសត្រូវក្នុងការតាមដានដើម្បីឱ្យប្រាកដថា សាលារៀនបានអនុវត្តផែនការនិរន្តរភាពរបស់ពួកគេតាមការគ្រោងទុក ។



ការតាំងចិត្តរបស់ក្រុប្រឹក្សាឃុំក្នុងវិស័យអប់រំ ៖ ក្រុមប្រឹក្សាឃុំប្រជុំតាមដានអំឡុងពេលត្រីមាសនេះ នៅឯសាលាឃុំព្រៃជ្រូក ក្នុងខេត្តសៀមរាប

## សមាសភាគ២ ៖ ការបង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

### កម្មវិធីអាហារូបករណ៍

កម្មវិធីអាហារូបករណ៍ដែលគាំទ្រដល់សិស្សថ្នាក់បឋមសិក្សាបច្ចុប្បន្នត្រូវបានផ្ទេរការទទួលខុសត្រូវទាំងសកម្មភាព និងថវិកាទៅឱ្យក្រុមប្រឹក្សាឃុំ និងសាលារៀនខ្លួនឯងផ្ទាល់ ។ ក្រុមការងារក្នុងសមាសភាគនេះ បានជួបជាមួយគណៈកម្មការកម្រងសាលារៀនកាលពីខែកុម្ភៈ ដើម្បីពិនិត្យឡើងវិញនូវដំណើរការនៃសកម្មភាពនេះ ។ ទោះជាយ៉ាងណាក៏ដោយការចាយវាយថវិកាមានការយឺតយ៉ាវនៅតាមកន្លែងមួយចំនួនដោយសារតែការផ្ទេរការទទួលខុសត្រូវនេះ ប៉ុន្តែសម្ភារៈទាំងអស់ត្រូវបានរាយការណ៍ថា បានបែងចែកដល់សិស្សក្រីក្ររួចរាល់អស់ហើយ ។ មានសិស្សសរុបចំនួន ៤៥៤នាក់ ក្នុងនោះមានសិស្សស្រីចំនួន២៤២នាក់ (%៥៣) កំពុងទទួលអាហារូបករណ៍ ។ ការិយាល័យ IBEC នៅតាមខេត្តបានរាយការណ៍ថា មានសាលាបឋមសិក្សាចំនួន ២០កំពុងទទួលការគាំទ្រដោយសកម្មភាពនេះតាមរយៈធនធានផ្ទាល់ខ្លួនរបស់ពួកគេ និងមានការសហការជាមួយឃុំ ។ មិនមានអត្រាសិស្សបោះបង់ត្រូវបានរាយការក្នុងត្រីមាសនេះទេ ។

នៅកម្រិតមធ្យមសិក្សា សិស្សអាហារូបករណ៍ជំនាន់ទី៣ (សិស្សរៀននៅថ្នាក់ទី៧ក្នុងឆ្នាំទី៣) បានកំពុងរៀនក្នុងថ្នាក់ទី៩ ។ របាយការណ៍បានបញ្ជាក់ថាមានយុវជនងាយរងគ្រោះចំនួន៦៥៩នាក់កំពុងទទួលអាហារូបករណ៍ ថយចុះពីចំនួន៧១២នាក់កាលពីដើមឆ្នាំ(ថយចុះចំនួន៧%)ដោយសារតែការបោះបង់ ។ ការបែងចែកសម្ភារៈសិក្សា (ប៊ិច និងសៀវភៅ) ត្រូវបានធ្វើឡើងដល់គ្រប់សិស្សទាំងអស់កាលពីខែកុម្ភៈ ឆ្នាំ២០១៤ ក្នុងឆមាសទី២ នៅតាមសាលារៀនទាំង៣៦ ក្នុងខេត្តទាំង៣ ។  ការិយាល័យ IBEC តាមខេត្តបានរាយការណ៍ថា ខណៈពេលដែលសិស្សអាហារូបករណ៍ចំនួន ៩៤%បានប្រឡងជាប់ឆមាសទី១ មានសិស្សបោះបង់បន្ថែមចំនួន៣៩នាក់ទៀតក្នុងត្រីមាសនេះដែលធ្វើឱ្យចំនួនសរុបកើនដល់ចំនួន៩២នាក់ (១៣%នៃចំនួនសរុប ស្រី១៥%)ក្នុងឆ្នាំនេះ ។ សំនួនសរុបដែលនៅសល់មាន៦២០នាក់ (ស្រី៣៩៦នាក់) ។

***សុបិនចង់ក្លាយជាគ្រូបង្រៀន***



អាន ចាន់រដ្ឋ ជាសិស្សថ្នាក់ទី៩ នៃវិទ្យាល័យប៊ុន រ៉ានី ហ.ស ស្ទឹ មិតក្នុងស្រុកចំការលើ ខេត្តកំពង់ចាម ។ ឪពុករបស់នាងឈ្មោះ ម៉េង គឹមអាន ជាកម្មករសំណង់ក្នុងទីក្រុងភ្នំពេញ ។ ម្តាយរបស់នាងឈ្មោះ ប៊ិន សារ៉ុម ជាកសិករ និងមើលការខុសត្រូវកូនទាំង៣ និងម្តាយជរានៅផ្ទះ ។ ឪពុកម្តាយ ចាន់រដ្ឋធ្លាប់បានបង្ខំឱ្យនាងបោះបង់ចោលការសិក្សា និងរកការងារធ្វើជាអ្នកបម្រើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ប៉ុន្តែនាងបានបដិសេធគំនិតនេះ ។ នាងចូលចិត្តការសិក្សា និងមានមហិច្ឆតាចង់ក្លាយជាគ្រូបង្រៀនទៅអនាគតប្រសិនបើអាច ។ ចាន់រដ្ឋ និយាយថា ការទទួលអាហារូបករណ៍ពី IBEC ធ្វើឱ្យនាងខិតខំសិក្សា ហើយនាងធ្លាប់បានណែនាំមិត្តរបស់នាងម្នាក់ដែលចង់បោះបង់ចោលការសិក្សាដើម្បីទៅរកការងារធ្វើនៅភ្នំពេញឱ្យបន្តការសិក្សាតទៅទៀត ។ ជាមួយនឹងកញ្ចប់អាហារូបករណ៍របស់នាង ចាន់រដ្ឋ បានប្រើប្រាស់ចំណេះដឹងបំណិនជីវិតរបស់នាងក្នុងការចិញ្ចឹមជ្រូក ។ គ្រួសាររបស់នាងទទួលបានជ្រូកតាមរយៈកម្មវិធីសាលារៀនជួយគ្រួសាររបស់ IBEC (គាំទ្រដោយ EDA) និងចាប់តាំងពីពេលនោះមក នាងបានលក់ជ្រូកដែលនាងចិញ្ចឹមបានចំនួន៤ដងរួចមកហើយ ។ គ្រួសាររបស់នាងបានប្រើថវិកាពីការលក់ជ្រូកនោះដើម្បីទិញកូនជ្រូកបន្ថែម និងឧបត្ថម្ភដល់ការសិក្សារបស់នាង និងប្អូនប្រុសស្រីរបស់នាង ។

## សមាសភាគ៣ ៖ ការកែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

ក្នុងត្រីមាសនេះក្រុមការងារក្នុងសមាសភាគនេះបានផ្តោតលើការដឹកនាំស្រាវជ្រាវដើម្បីកំណត់ឱ្យច្បាស់នូវចំនួនគ្រូដែលឈប់ក្នុងចំណោមគ្រូទាំងអស់ដែលយើងបានបំប៉នក្នុងខេត្តទាំង៣ ។ ដូចដែលបានបង្ហាញក្នុងរបាយការណ៍ផ្សេងៗ គម្រោងបានបង្ហាញពីកង្វល់អំពីការផ្ទេរបស់គ្រូពីសាលារៀនមួយទៅសាលារៀនមួយទៀតពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើឱ្យមានការបំប៉នឡើងវិញដល់ នាយកសាលា លោកគ្រូ អ្នកគ្រូ បណ្ណារក្ស គ្រូ ICT ជាដើម ។ ចំនួនគ្រូផ្ទេរដ៏ច្រើននេះបានធ្វើឱ្យប៉ះពាល់ដល់ផែនការនិរន្តរភាពនៅតាមតំបន់គោលដៅ វាពិតណាស់ថាគ្រូដែលផ្ទេរទាំងនោះនឹងយកជំនាញដែលពួកគេបានរៀនទៅកាន់សាលារៀនដទៃទៀត ។ ទោះជាយ៉ាងណាក៏ដោយការបង្កើតគម្រោង ផ្អែកទៅលើទំនុកចិត្តដែលសាលារៀនអាចអនុវត្តទៅបានតាមផែនការសហការគ្នាពីមួយទៅមួយ ។ នាយកសាលាត្រូវបានបំប៉នពីរបៀបជួយគ្រូ ជួយ បណ្ណារក្ស និងគ្រូកុំព្យូទ័រ ចំណែកបណ្ណារក្សបំប៉នពីរបៀបជួយគ្រូ និងក្រុមប្រឹក្សាកុមារបំប៉នពីរបៀបសហការជាមួយនាយកសាលា និងគ្រូ ជាដើម ។ យើងអាចនិយាយមួយបែបទៀតថា *ការសហការប្រសើរជាងការធ្វើតែឯង* ដូច្នេះនៅពេលដែលគ្រូមានជំនាញផ្សេងៗគ្នាផ្ទេរទៅកាន់សាលារៀនដទៃ វាធ្វើឱ្យយើងបារម្ភថាពួកគេអាចប្រើប្រាស់ជំនាញទាំងនោះមានប្រសិទ្ធិភាពដូចក្នុងសាលារៀនដែលពួកគេទទួលការបំប៉នឬទេ ។ សមាសភាគនេះបានធ្វើការអង្កេតស្រដៀងគ្នានេះទៅលើនាយកសាលា បណ្ណារក្ស និងគ្រូ ICT ដើម្បីធ្វើរបាយការណ៍ដាក់ជូន USAID និងក្រសួង អ.យ.ក ធ្វើការពិនិត្យសម្រាប់ជាមេរៀនបទពិសោធន៍សម្រាប់គម្រោងផ្សេងៗទៅថ្ងៃអនាគត ។

# សមាសភាគ៤ ៖ ការកែលម្អបរិបទទំនាក់ទំនងអប់រំ

## *ការអប់រំបំណិនជីវិត ៖*



*ការទទួលបានទិន្នផលខ្ពស់ពីសួនបំណិនជីវិត : សាលារៀនក្នុងខេត្តសៀមរាប បានប្រើជំនាញបំណិនជីវិតក្នុងការដាំម្ទេសក្នុងទីធ្លាដ៏ធំដែលនឹងបង្កើនប្រាក់ចំណូលសម្រាប់ការផ្តើយតបទៅថ្ងៃអនាគត*

ក្នុងត្រីមាសនេះកម្មវិធីបំណិនជីវិតបានផ្តោតលើការតាមដាន និងបែងចែកសម្ភារៈបង្រៀន និងរៀនដែលរួមមានសៀវភៅបំណិនជីវិតសម្រាប់គ្រូ សន្លឹកអ៊ុតសម្រាប់សិស្ស និងផូស្ទ័រសម្រាប់ការបង្រៀន និងរៀន ។ ៩៣% នៃសៀវភៅបំណិន ជីវិត (សរុប ២៨ប្រធានបទ) ត្រូវបានអនុម័តដោយគណៈកម្មការត្រួតពិនិត្យសៀវភៅសិក្សា និង២ប្រធានបទទៀត ត្រូវបានច្រានចោលដោយហេតុថាខ្វះអ្នកជំនាញក្នុងការត្រួតពិនិត្យពាក់ព័ន្ធ និងនយោបាយ ។

សមាសភាគនេះបានរាយការណ៍ថា សាលាមធ្យមសិក្សាចំនួន១១៣បានកំពុងបង្រៀនកម្មវិធីបំណិនជីវិតក្នុងឆ្នាំនេះបើទោះជាគ្មានការគាំទ្រថវិកាដល់សាលារៀនក៏ដោយ ។ សេចក្តីរាយការណ៍នេះហាក់មានប្រសិទ្ធិភាពដល់ការខំប្រឹងប្រែងដើម្បីនិរន្តរភាពនៃកម្មវិធីបំណិនជីវិត ។ មានសិស្សសរុបចំនួន២៣,០០០នាក់នៅថ្នាក់មធ្យមសិក្សាកំពុងទទួលបានការបង្រៀនកម្មវិធីបំណិនជីវិតស្តីពីប្រធានបទសំខាន់បី (អាជីពងាយ  បញ្ហាសង្គមក្នុងមូលដ្ឋាន និងសេដ្ឋកិច្ចអាជីវកម្ម) ក្នុងខេត្តគោលដៅទាំង៦ក្នុងឆ្នាំនេះ ។

## *ការបណ្តុះបណ្តាលគ្រូ ៖*

ក្រុមសមាសភាគនេះ បានដឹកនាំសិក្ខាសាលារំលឹកឡើងវិញពីមួយទៅមួយក្នុងត្រីមាសនេះ ។ សិក្ខាសាលាជុំទី១ក្នុងខេត្តទាំងបីផ្តោតលើ ការលើកកម្ពស់ការអាន និងសរសេរដល់គ្រូថ្នាក់ទី១ ។ គ្រូបានពិនិត្យ និងប្រើប្រាស់នូវសម្ភារៈបង្រៀនថ្មីៗ ឧបករណ៍វាយតម្លៃ និងរៀបចំកៀនអានក្នុងថ្នាក់របស់ពួកគាត់ ។ សកម្មភាពត្រួតពិនិត្យ និងតាមដាន បានរកឃើញនូវហេតុផលដ៏ល្អមួយដែលស្របទៅនឹងខ្លឹមសារសិក្ខាសាលា ។ ក្នុងន័យនេះ ៧៥%នៃការអង្កេតថ្នាក់រៀនទទួលបានពិន្ទុល្អ តាមរយៈទម្រង់ត្រួតពិនិត្យសកម្មភាពស្តង់ដារ ១៥% បង្ហាញពីភាពពេញចិត្ត ខណៈពេលដែលប្រហែល ១០%បង្ហាញពីភាពមិនពេញចិត្ត ។ សមាសភាគនេះក៏បានធ្វើការជាមួយសាលារៀនបំភ្លឺផ្លូវចំនួន២១ផងដែរក្នុងការរៀបចំឡើងវិញនូវថ្នាក់មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្រ្ត និងសិក្សាសង្គម និងផ្តល់នូវសម្ភារៈថ្មីៗក្នុងការដំណើរការនេះ ។



*ការព្យាយាមបង្កើតបរិស្ថានសិក្សាដ៏សំបូរបែបសម្រាប់ការអាន និងសរសេរ ៖ គ្រូថ្នាក់ទី១កំពុងធ្វើតេស្តសម្ភារៈបង្រៀន និងឧបករណ៍វាយតម្លៃ ដើម្បីតាមដានការសិក្សារបស់សិស្ស*

## *ការគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន ៖*



*ការសិក្សាជាមួយក្តីសង្ឃឹម ៖ យុវជនកម្ពុជាប្រើប្រាស់បន្ទប់ ICT ដើម្បីទទួលបានជំនាញកុំព្យូទ័រ ក្នុងបន្ទប់កុំព្យូទ័ររបស់ IBEC ក្នុងខេត្តកំពង់ចាម*

សមាសភាគរងមួយនេះបានឈានដល់គោលដៅរបស់ខ្លួនក្នុងការកសាងបន្ទប់កុំព្យូទ័រឱ្យដល់ចំនួន២៦ក្នុងត្រីមាសចុងក្រោយនេះ ។ បន្ទប់កុំព្យូទ័រទី២៦ត្រូវបានកសាងចប់រួចរាល់នៅវិទ្យាល័យកំពង់ក្តីក្នុងខេត្តសៀមរាប ។ វគ្គបំប៉នគ្រូស្តីពីកាប្រើប្រាស់ពុម្ពអក្សរយូនីកូដ និងកម្មវិធីការិយាល័យខ្មែររបស់ក្រសួង អ.យ.ក ក៏បានធ្វើឡើងក្នុងត្រីមាសនេះដែរ ។ គ្រូក៏ត្រូវបានផ្តល់ការណែនាំក្នុងការប្រើប្រាស់ឧបករណ៍ ICT ក្នុងការបង្រៀន និងការបញ្ចូល ICT ក្នុងការបង្រៀនប្រចាំថ្ងៃ ។ ការតាមដាន និងការគាំទ្រផ្នែកបច្ចេកទេសក៏ត្រូវបានផ្តល់ដល់សាលារៀនចំនួ២៥ផ្សេងទៀតដែលទទួលបានបន្ទប់កុំព្យូទ័រចាប់តាំងពីឆ្នាំដំបូងផងដែរ

**ដៃគូគម្រោង** IBEC គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ គម្រោងត្រូវបានប្រតិបត្តិដោយអង្គការអប់រំពិភពលោកដោយមានកិច្ចសហការជាមួយអង្គការខេប និងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។ ដៃគូក្នុងស្រុកផ្សេងទៀត មានអង្គការ ៖ WCRD, BSDA, NEP, EDA និង Media One

*ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។*
*រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*
*ការិយាល័យអង្គការអប់រំពិភពលោក ៖ ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១៦ ៨៥៤* E-mail: worldedcam@worlded.org.kh